# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/៩៥៦ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងក្រុមប្រឹក្សាកំណែទម្រង់ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត "គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ដើម្បីដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានបេសកកម្មដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវ និងរៀបចំផែនការយុទ្ធសាស្ត្រ ព្រមទាំងកម្មវិធីសកម្មភាពសម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមគោលនយោបាយ និងចក្ខុវិស័យនៃការកែទម្រង់របស់រាជរដ្ឋាភិបាល
- លើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច អំពីផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាព ព្រមទាំងវិធានការចាំបាច់នានាដែលបម្រើឱ្យការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមចក្ខុវិស័យកំណែទម្រង់របស់រាជរដ្ឋាភិបាល
- ជំរុញ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាល
- ចេញសេចក្តីណែនាំចាំបាច់នានា ដល់គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពសម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលបណ្តាសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពសម្រាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ដាក់ឱ្យដំណើរការនូវវិធានការចាំបាច់នានាសម្រាប់ការកែទម្រង់ប្រព័ន្ធតុលាការ បន្ទាប់ពីទទួលបានការឯកភាពពីរាជរដ្ឋាភិបាល
- ធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ដើម្បីកៀរគរធនធានសម្រាប់ការអនុវត្តគម្រោងនានា ដែលបម្រើឱ្យការងារកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌
- ដាក់ឱ្យអនុវត្ត និងអភិវឌ្ឍនូវគម្រោងសាកល្បងនានា ដែលបម្រើឱ្យការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាអាទិ៍ គម្រោងតុលាការគំរូ គម្រោងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ផ្សព្វផ្សាយព័ត៌មាន ស្តីពីសកម្មភាព និងសមិទ្ធផលនានានៃការងារកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

**មាត្រា ៣.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១ រូប | ជាអនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | | ជាសមាជិក |
| - អនុប្រធានតុលាការកំពូល | ០១ រូប | ជាសមាជិក |
| - អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល | ០១ រូប | ជាសមាជិក |
| - ប្រធានសាលាឧទ្ធរណ៍ | | ជាសមាជិក |

| | | |
|---|---|---|
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | | ជាសមាជិក |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ០១ រូប | ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | ០១ រូប | ជាសមាជិក |
| - តំណាងអង្គភាពប្រឆាំងអំពើពុករលួយ | ០១ រូប | ជាសមាជិក |
| - ប្រធានលេខាធិការដ្ឋាន | | ជាសមាជិក |

ការតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា ៤.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បើកកិច្ចប្រជុំរបស់ខ្លួន តាមការអញ្ជើញរបស់ប្រធាន យ៉ាងតិច ១ ដង ក្នុង ១ ឆមាស។ ប្រធានអាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ តាមការចាំបាច់។ ក្នុងករណីអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំបាន។

**មាត្រា ៥.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ជាសេនាធិការ សម្រាប់គាំទ្រដំណើរការការងាររបស់ខ្លួន។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់។ ប្រធាន និងអនុប្រធាន ព្រមទាំងសមាជិកនៃលេខាធិការដ្ឋានត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ៦.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា ៧.-**

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌។

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិទទួល និងគ្រប់គ្រងធនធានដែលបានមកពីប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ